នៃយោធភូមិភាគនីមួយៗ ។ ចំពោះសមាសភាពនិងភារកិច្ចរបស់អនុគណៈកម្មការ និងក្រុមការងារនីមួយៗ អាស្រ័យដោយ គណៈកម្មការជាអ្នករៀបចំ និងកំណត់ជាក់ស្តែង ។

**មាត្រា ៤ :** គណៈកម្មការនេះមានភារកិច្ចសហការជាមួយកងយោធពលភូមិន្ទថៃ ដើម្បីពិគ្រោះគ្នាដោះស្រាយអោយបានល្អ នូវរាល់បាតុភាព ឧប្បទ្ទវហេតុផ្សេងៗដែលកើតឡើងនៅតាមព្រំដែន កម្ពុជា_ថៃ បង្កើតឡើងនូវបរិយាកាស សន្តិសុខ សុវត្ថិភាព នៅតាមបណ្តោយព្រំដែននៃប្រទេសទាំងពីរ ។

**មាត្រា ៥ :** ទីកន្លែងធ្វើការរបស់គណៈអចិន្ត្រៃយ៍ នៃ គណៈកម្មការកំណត់យកទីបញ្ជាការដ្ឋានការពារព្រំដែនអគ្គសេនាធិការ ។

**មាត្រា ៦ :** គណៈកម្មការមានសិទ្ធប្រើប្រាស់ត្រារបស់ក្រសួងការពារជាតិ ។
គណៈអចិន្ត្រៃយ៍មានសិទ្ធិប្រើប្រាស់ត្រារបស់អគ្គសេនាធិការ ។

**មាត្រា ៧ :** ចាត់ទុកជានិរាករណ៍នូវអនុក្រឹត្យលេខ ០៧ អនក្រ ចុះថ្ងៃទី ១៦ មករា ១៩៩៥ ។

**មាត្រា ៨ :** ទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ នាយអគ្គសេនាធិការ រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ស្ថាប័នពាក់ព័ន្ធ និង សាមីជនដែលមានឈ្មោះក្នុងប្រការ ១និងប្រការ២ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ។

**មាត្រា ៩ :** អនុក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានិងចុះហត្ថលេខាតទៅ ។

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
| ព្រះហស្តលេខានិងត្រា | ហត្ថលេខានិងត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

***

*រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៥*

# អនុក្រឹត្យលេខ ៣០ អនក្រ
# ស្តីពីការបង្កើតគណៈកម្មាធិការឥណទានសំរាប់អភិវឌ្ឍន៍ជនបទ

_បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

www.pheakdeylaw.com

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រឹត្យត្រាស់បង្គាប់អោយកែសំរួលសមាសភាពរាជរដ្ឋាភិបាល លេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤

-បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលត្រូវបានប្រកាសអោយប្រើជាផ្លូវការដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

## សំរេច

**មាត្រា ១ :** បង្កើតគណៈកម្មាធិការឥណទានសំរាប់អភិវឌ្ឍន៍ជនបទ ដែលមានអក្សរកាត់ " គជទាន " ភ្ជាប់ជាមួយក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និង ជនបទ ហើយមានទីតាំងនៅរាជធានីភ្នំពេញនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២ :** គជទានមានសមាសភាពដូចតទៅ :

១-ឯកឧត្តម **ហុង ស៊ុនហួត** រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ ជាប្រធាន

២-ឯកឧត្តម **ឈា សុខ** រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាអនុប្រធាន

៣-តំណាងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ជាសមាជិក

៤-តំណាងអង្គការមិនមែនរដ្ឋាភិបាល បីនាក់ ជាសមាជិក

៥-តំណាងធនាគារជាតិនៃកម្ពុជា ជាសមាជិក

៦-ឯកឧត្តម **ឆា អ៊ាវហួ** ទីប្រឹក្សាទេសរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការទីតិសម្បទា និង អភិវឌ្ឍន៍អនុប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអគ្គលេខាធិការនៃគជទាន ហើយនឹងជានាយករបស់អង្គភាពបច្ចេកទេសអចិន្ត្រៃយ៍ ដែលមានភារកិច្ចជួយការងារទូទៅ និងការងារប្រចាំថ្ងៃ របស់ គជទាន ។

សមាជិកទាំងអស់ត្រូវចូលរួមប្រជុំតាមសេចក្តីអញ្ជើញរបស់ប្រធាន គជទាន ។ ក្នុងករណីចាំបាច់គជទានអាច អញ្ជើញតំណាងក្រសួងនានា ដែលពាក់ព័ន្ធចូលរួមប្រជុំ ។

សមាជិកទាំងអស់មានសំលេងស្មើគ្នាក្នុងអង្គប្រជុំ ។ ក្នុងករណីមានសំលេងស្មើគ្នា សំលេងប្រធានអង្គប្រជុំជាសំលេងមានឧត្តមភាព ។

www.pheakdeylaw.com

**មាត្រា ៣ :** អង្គភាពបច្ចេកទេសមួយត្រូវបានបង្កើតឡើង ដើម្បីជាលេខាធិការ ឥណទាន ។ អង្គភាពបច្ចេកទេសនេះត្រូវស្ថិតនៅក្រោមការទទួលខុសត្រូវរបស់លោកនាយកអង្គភាព ។

អង្គភាពអាចទទួលជំនួយបច្ចេកទេស និង ជំនួយផ្សេងៗទៀតពីអង្គការជាតិ និងអន្តរជាតិ ដើម្បីជួយដល់ដំណើរការ នៃការងាររបស់ខ្លួន ។

**មាត្រា ៤ :** ឥណទាន មានភារកិច្ចដូចតទៅ:

ក-លើកឡើងនូវយុទ្ធសាស្ត្រអភិវឌ្ឍន៍ឥណទានជនបទជូនរាជរដ្ឋាភិបាលដោយៈ

- រៀបចំក្របខ័ណ្ឌនីតិសាស្ត្រសំរាប់អនុវត្តនយោបាយជាតិក្នុងវិស័យសន្សំសំចៃ និង ឥណទាន សំរាប់អភិវឌ្ឍន៍ជនបទ និង កសិកម្ម ។
- កំណត់នយោបាយនៃការសន្សំសំចៃ និង ឥណទាន ហើយនឹងក្របខ័ណ្ឌនីតិវិធីអោយស្រប នឹងលក្ខណៈពិសេសរបស់ឥណទានជនបទ ។
- ទទួលរៀបចំឯកសារសំរាប់ហ្វឹកហ្វឺនក្របខ័ណ្ឌជាតិផ្នែកឯកទេសនៃប្រព័ន្ធសន្សំសំចៃ និង ឥណទាន សំរាប់អភិវឌ្ឍន៍ជនបទ ដើម្បីជួយប្រតិបត្តិករ និង អនាគតវិជ្ជាស្ថាន ផ្នែកឥណទានព្រមទាំងបំរើការក្នុងរដ្ឋបាលដែលពាក់ព័ន្ធវិស័យនេះ ។

ខ-គ្រប់គ្រងការប្រើប្រាស់ឥណទានជនបទអោយមានប្រសិទ្ធភាពដោយ :

- សំរបសំរួល និង តាមដានគ្រប់សកម្មភាពឥណទានសំរាប់អភិវឌ្ឍន៍ជនបទ ដើម្បីអោយការប្រើប្រាស់ឥណទានស្របតាមទិសដៅ និង ជៀសវាងការរង្គោះរង្គើរ និង រាំងស្ទះដល់ការអភិវឌ្ឍន៍ប្រព័ន្ធហិរញ្ញវត្ថុជាតិ ។
- សំរបសំរួលមធ្យោបាយទាំងឡាយ ដែលរាជរដ្ឋាភិបាលផ្តល់អោយ ដើម្បីអនុវត្តអោយបានល្អនូវនយោបាយជាតិក្នុងវិស័យនេះ ។

គ-ជួយពង្រឹងផ្នែកស្ថាប័ន និង ជួយជំរុញប្រតិបត្តិករឯកជនដោយ:

- កត់សំគាល់ លើកកំពស់ និង គាំទ្ររាល់សកម្មភាពសន្សំសំចៃ និង ឥណទាន ដែលបំរើដល់ការអភិវឌ្ឍន៍ជនបទ និងបង្កើនជីវភាពប្រជាជនក្រីក្រ និង ជួយជំរុញប្រព័ន្ធហិរញ្ញវត្ថុជាតិអោយអាចបំពេញសេចក្តីត្រូវការលើការសន្សំ និង ឥណទាននៅទូទាំងប្រទេស ។
- លើកទឹកចិត្តប្រតិបត្តិករថ្មីតាមន័យដូចបានបញ្ជាក់ខាងលើ ដែលជួយផ្តល់ឥណទានបន្ថែមលើប្រតិបត្តិករដែលមានរួចហើយ ។

www.pheakdeylaw.com

-ជួយរិះរកមធ្យោបាយផ្សេងៗ ដើម្បីជំរុញអោយមានការបង្កើតធនាគារពាណិជ្ជកម្មតាមខេត្ត ដែលអាចធ្វើប្រព័ន្ធ ហិរញ្ញវត្ថុអាចមានការងាយស្រួលក្នុងការផ្ទេរ-ផ្ទេរមូលនិធិ គ្រប់គ្រងធនធានខ្លួនបាន និងជួយបង្កើតធនធានឥណទានសំរាប់អភិវឌ្ឍន៍សេដ្ឋកិច្ច ។

ឃ-រៀបចំកម្មវិធី និង ផែនការដើម្បីបង្កលទ្ធភាពងាយស្រួលក្នុងការគៀងគរ ជំនួយពី បរទេស សំរាប់គំរូវការឥណទាន ។

-កំណត់ទិសដៅ និង សំរបសំរួលជំនួយទ្វេភាគី និងពហុភាគីក្នុងវិស័យឥណទានជនបទ ។

**មាត្រា ៥ :** អង្គភាពបច្ចេកទេសរបស់ គជទាន មានភារកិច្ចដូចតទៅ :

-អនុវត្តការងារប្រចាំថ្ងៃរបស់ គជទាន

-រៀបចំរាល់សំណុំរឿងទាក់ទិននឹង គជទាន ដើម្បីដាក់ជូន គជទានពិនិត្យ និង អនុម័ត ។

-សំរបសំរួលការងារប្រតិបត្តិករទាំងអស់ ដែលប្រើប្រាស់ឥណទាន សំរាប់អភិវឌ្ឍន៍ជនបទ ។

**មាត្រា ៦ :** នាយក ក៏ដូចជាអង្គភាពបច្ចេកទេសត្រូវបានតែងតាំងឡើងសំរាប់រយៈពេលគ្រប់គ្រាន់ ដើម្បីបំពេញអាណត្តិក្នុងការ អភិវឌ្ឍន៍ឥណទានជនបទតាមកម្មវិធីផ្តល់ជំនួយ ។

**មាត្រា ៧ :** រាល់អនុក្រឹត្យ និង សេចក្តីសំរេចពីមុន ដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ៨ :** គជទាន និង រាល់ក្រសួង ស្ថាប័ននានាដែលមានការពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃឡាយព្រះហស្ថលេខា និង ចុះហត្ថលេខានេះតទៅ ។

| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
|---|---|
| ព្រះហស្ថលេខា និងត្រា | ហត្ថលេខានិងត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

* * *

*រាជធានីភ្នំពេញ,ថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៥*

## អនុក្រឹត្យលេខ ៣១ អនក្រ
## ស្តីពីការបំពេញបន្ថែមក្នុងប្រាក់បំណាច់សំរាកការងារ
## របស់មន្ត្រីរាជការ និយោជិក កម្មករ ប្រចាំឆ្នាំ ១៩៩៥

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

www.pheakdeylaw.com